# ការបង្ហាញព័ត៌មានទាន់ពេល

ឈ្មោះក្រុមហ៊ុនចុះបញ្ជី : រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

លេខកូដក្រុមហ៊ុនចុះបញ្ជី : KH1000010004

កាលបរិច្ឆេទ និងពេលវេលានៃការបញ្ជូន : ថ្ងៃទី 30 ខែកញ្ញា ឆ្នាំ២០២៤ ម៉ោង : 17 : 00 នាទី

## ហេតុការណ៍ពាក់ព័ន្ធនឹងចំណេញឬខាត ( ទម្រង់ ង.១ )

| ▼ ការថយចុះនៃចំណូល ចំណេញប្រតិបត្តិការ និងចំណេញសុទ្ធ | | | | |
|---|---|---|---|---|
| ១.ព័ត៌មាននៃការប្រែប្រួល | ត្រីមាសទី២ ឆ្នាំ២០២៤ | ត្រីមាសទី២ ឆ្នាំ២០២៣ | បម្រែបម្រួល | អត្រាបម្រែបម្រួល |
| - ចំណូល | ៩២.៥៩៨.៧១៨.០០០រៀល | ៩៩.៥៦២.៤៩៦.០០០រៀល | (៦.៩៦៣.៧៧៨.០០០រៀល) | (៦,៩៩%) |
| - ចំណេញប្រតិបត្តិការ | ២៥.៨៣៣.៣៩៩.០០០រៀល | ៣៨.៦៨៥.៤៤៦.០០០រៀល | (១២.៨៥២.០៤៧.០០០រៀល) | (៣៣,២២%) |
| - ចំណេញសុទ្ធ | ២.៤២៥.៩២៨.០០០រៀល | ១៣.២៣១.២៩៩.០០០រៀល | (១០.៨០៥.៣៧១.០០០រៀល) | (៨១,៦៧%) |
| ២.មូលធនភាគហ៊ុនិក | ≥៣០ ប៊ីលានរៀល | | | |
| ៣.បរិយាយ | ក្នុងត្រីមាសទី២ ឆ្នាំ២០២៤ នេះ រ.ទ.ស.ភ មានចំណូលចំនួន ៩២.៥៩៨.៧១៨.០០០រៀល ថយចុះចំនួន ៦.៩៦៣.៧៧៨.០០០រៀល ឬ ៦,៩៩% ចំណេញប្រតិបត្តិការចំនួន ២៥.៨៣៣.៣៩៩.០០០រៀល ថយចុះចំនួន ១២.៨៥២.០៤៧.០០០រៀល ឬ ៣៣,២២% និង ចំណេញសុទ្ធចំនួន ២.៤២៥.៩២៨.០០០រៀល ថយចុះចំនួន ១០.៨០៥.៣៧១.០០០រៀល ឬ ៨១,៦៧% បើធៀបនឹងត្រីមាសទី២ ឆ្នាំ២០២៣។ | | | |
| ៤.មូលហេតុ | មូលហេតុចម្បងនៃការថយចុះនៃចំណូល ចំណេញប្រតិបត្តិការ និងចំណេញសុទ្ធ នៅក្នុងត្រីមាសទី២ ឆ្នាំ២០២៤ គឺបណ្តាលមកពីកត្តាដែលនាំឱ្យមានការកើនឡើងអត្រាទឹកគ្មានចំណូលកើនដល់ ២៧,១៣% ដោយសារៈ<br>១. ការដាក់ឱ្យដំណើរការរោងចក្រផលិតទឹកស្អាតបាក់ខែងជំហានទី១ គឺបានបង្កប់ទីតាំងដែលខ្វះទឹក ហើយបន្ទាប់ពីដាក់ឱ្យដំណើរការនៅជំហានទី២ នៅអំឡុងខែមីនា ឆ្នាំ២០២៤កន្លងមក ដែលបានបង្កើនទាំង សមត្ថភាពផលិតទឹក និងសម្ពាធទឹកក្នុងរង្វង់ ២,៦បារ បន្ថែម បង្កឱ្យមានការលេចធ្លាយច្រើន ជាហេតុបណ្តាលឱ្យអត្រាទឹកគ្មានចំណូលកើនខ្ពស់គួរឱ្យកត់សម្គាល់ ក្រោយពិនិត្យឃើញលទ្ធផលនៃបរិមាណទឹកប្រកាសវិក្កយបត្រ ធៀបទៅនឹងបរិមាណទឹកផលិតខុសគ្នាច្រើន ចាប់ពីដើមត្រីមាសទី២ ឆ្នាំ២០២៤។ សូមបញ្ជាក់ផងដែរថា ការផលិតទឹកអតិបរមាចាប់ពីដើមខែមេសា ឆ្នាំ២០២៤ ជាមធ្យមប្រចាំថ្ងៃប្រមាណ ៩២០.០០០ម៣ក្នុងមួយថ្ងៃ និងបច្ចុប្បន្នប្រមាណ ៨៣០.០០០ម៣ក្នុងមួយថ្ងៃ ខណៈសម្ពាធទឹកចុងបំពង់ក្នុងការផ្គត់ផ្គង់ទឹកនៅរក្សាដដែល។<br>២. ក្នុងនោះផងដែរទីតាំងលេចធ្លាយគិតត្រឹមរយៈពេល ៧ខែ ដូចគ្នាក្នុងឆ្នាំ២០២៣ មានចំនួន ២.៤៧៥កន្លែង និងឆ្នាំ២០២៤ មានចំនួន ៣.១៦៥កន្លែង មានការកើនឡើងចំនួន ៦៩០កន្លែង ដែលស្មើនឹង ២៧,៨៧%។<br>៣. នាឡិកាមេនៅតាមបណ្តារោងចក្រផលិតចាស់មានអាយុកាលប្រើប្រាស់យូរឆ្នាំ បន្ទាប់ពីការត្រួតពិនិត្យឡើងវិញឃើញថាមានកម្រិតលម្អៀងនាឡិកាតាមរោងចក្រទាំងអស់មានកម្រិតលម្អៀងៈ<br>• រោងចក្រភូមិព្រែក១ : កម្រិតលម្អៀងប្រមាណ -៦,៤២%<br>• រោងចក្រភូមិព្រែក២ : កម្រិតលម្អៀងប្រមាណ -២២,៤៧%<br>• រោងចក្រជ្រោយចង្វារ : កម្រិតលម្អៀងប្រមាណ -១,១៥%<br>៤. ផ្អែកតាមតារាងតុល្យការទឹក ត្រីមាសទី២ ឆ្នាំ២០២៤ ឃើញថាបរិមាណទឹកបាត់បង់រកមិនឃើញ (ប៉ាន់ស្មាន) កើនរហូតដល់ ២០.០៧១.៣១០ម៣។<br>៥. ការងារគ្រប់គ្រងសម្ពាធតាមអនុតំបន់ក្នុងក្រុងចំនួន ១៧អនុតំបន់ ពុំអាចអនុវត្តទាន់ពេលវេលា អំឡុងពេលការដាក់រោងចក្របាក់ខែងទាំងពីរជំហានឱ្យដំណើរការ ដែលជាហេតុធ្វើឱ្យសម្ពាធទឹកកើនខ្ពស់នាំឱ្យមានការលេចធ្លាយច្រើន។ សូមបញ្ជាក់ផងដែរថា ការរៀបចំកែសម្រួលអនុតំបន់ និងដំឡើងវ៉ាន់បន្ថយសម្ពាធទឹក (PRV) ត្រូវចំណាយពេលជិតមួយឆ្នាំ ទើបអនុវត្តចប់។ | | | |

- ឯកសារភ្ជាប់: ព័ត៌មានហិរញ្ញវត្ថុចន្លោះពេលពង្រួមសម្រាប់ត្រីមាស និងរយៈពេល៦ខែ បញ្ចប់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤។

ហត្ថលេខានិងឈ្មោះបុគ្គលិកទទួលបន្ទុក

ក្នុងការផ្តល់ព័ត៌មាន